ផ្នែកបទភ្លេងវិញ **សុជាខ្ញុំ**មិនធ្លាប់បានរៀនពីគ្រូណាទេ ប៉ុន្តែបើខ្ញុំមានឱកាសកាន់ឧបករណ៍ភ្លេងបានប្រហែលមួយម៉ោង ខ្ញុំអាចដេញត្រូវបានមួយបទឬពីរបទភ្លាម ព្រោះខ្ញុំចេះធ្វើបទភ្លេងតាមមាត់ ហើយរាវរកសម្លេងភ្លេងតាមសូរមាត់ខ្ញុំនោះឯង ។ ផ្នែកចម្លាក់និងគំនូរ ខ្ញុំមិនជាចេះណាស់ណាទេ ប៉ុន្តែបើក្នុងចំណោមនោះ មិនមានអ្នកចេះ ខ្ញុំក៏អាចធ្វើបាន តួយ៉ាងដូចជាបទុមចេតិយដែលកំពុងកសាង **សុជាខ្ញុំ**ជាអ្នកគូរឲ្យចេញជារូបរាងដំបូង ។ មយ៉ាងទៀត ក្នុងនាមខ្ញុំជាកូនអ្នកស្រែ សិល្បៈធ្វើស្រែចម្ការដូចជា ភ្ជួរ រាស់ សាបព្រោះ ដកស្ទូង ច្រូតកាត់ បោកបែនជាដើម **សុជាខ្ញុំ**ចេះយ៉ាងស្ទាត់ និងធ្លាប់ប្រព្រឹត្តធ្វើយ៉ាងសកម្ម ។

# ផ្នែកសុខភាព

**សុជាខ្ញុំ** បើនិយាយពីសុខភាពហាក់បីដូចជាចម្លែកណាស់ បើប្រៀបទៅនឹងមនុស្សធម្មតា ព្រោះអ្នកម្តាយជំណាលប្រាប់ថា កាលខ្ញុំអាយុបាន ៦ ខែ មានរឿងអស្ចារ្យមួយកើតឡើង រឿងនោះគឺ "ថ្ងៃមួយ វេលាម៉ោង ១២ ថ្ងៃត្រង់ នៅឯរោងការដ្ឋាន ម្តាយមីងខ្ញុំឈ្មោះ **អៀង ម៉ៅ** បានឃើញពស់ព្រៃមួយក្បាលនៅក្នុងប្រមូរកន្ទេល គាត់ក៏

*វាយសម្លាប់ពស់ព្រៃនោះ រួចយកទៅបោះចោលនៅខាងត្បូងរោង ។ លុះអ្នកម្ដាយមកពីធ្វើការ អ្នកមីងបាននាំអ្នកម្ដាយទៅមើលពស់ដែលងាប់ហើយ ឃើញថាពស់នោះលៀនអណ្ដាតចេញមកក្រៅ និងមានឈាមហូរចេញតាមច្រមុះនិងមាត់ជាច្រើន ។ យប់នោះ **សុជាខ្ញុំ** ចាប់ផ្ដើមតឹងពោះ ប្រកាច់សន្លប់ឈឹង លៀតអណ្ដាត និងមានឈាមហូរចេញតាមច្រមុះនិងមាត់ មានអាការដូចជាពស់ដែលអ្នកម្ដាយបានឃើញពីថ្ងៃ ។ យប់នោះ **សុជាខ្ញុំ**ប្រកាច់របៀបនេះ ៣ ដង លោកឪពុកអ្នកម្ដាយមិនបានសម្រាន្ដទេ” ។ ចាប់ពីពេលនោះមក ខ្ញុំមានជម្ងឺបែបនេះជារៀងរហូត គ្រាន់តែមានការរង្វើលជាងមុន ជួនកាលមួយថ្ងៃ ២ ដង មួយថ្ងៃម្ដង ពីរថ្ងៃម្ដង បីថ្ងៃម្ដង មួយអាទិត្យម្ដង កន្លះខែម្ដង គឺថយជាលំដាប់ រហូតដល់អាយុ ១២ ឆ្នាំទើបជម្ងឺនោះបានជាសះស្បើយ ។ សុជាខ្ញុំធ្លាប់ឮចាស់ ៗ ហៅសួរ ថា “អាអូនអ្ហើយ! តើបានយើង ឬបានគេ ចៅ? ” ពាក្យនេះ គឺគេប្រើសម្រាប់អ្នកឈឺច្រើន អ្នកស្រុកខ្លះថាខ្ញុំជាមនុស្សឆ្កួតជ្រូក ខ្លះគិតថា **សុជាខ្ញុំ**ប្រហែលជាក្លាយជាមនុស្សល្ងីល្ងើមិនដឹងអី ព្រោះពេលនោះ ខ្ញុំសន្លប់ញឹកញាប់ពេក ធ្វើឲ្យការចងចាំមិនពូកែ គឺតែងតែភ្លេចភ្លាំងដោយច្រើន ជួនកាលពាក្យខ្លះកំពុងតែ*

និយាយទើងមាត់ក៏ក្ដេចបាត់ដែរ ។ កាលពីមុន **សុជាខ្ញុំ** មានឈ្មោះថា **សាន សារី** ជូនទើងបងប្រុសខ្ញុំ **សាន សារុន** ប៉ុន្តែដោយឈឺច្រើន បែបនេះ ទើបប្រែក្លាយឈ្មោះថា **សាន សុខជា** ។ ក្រោយពេលបួស លោកគ្រូខ្ញុំបានកែថា **សាន សុជា** ដូច្នេះវិញ ។

## ផ្នែករបួសស្នាម

**សុជាខ្ញុំ** មានគ្រោះថ្នាក់ផ្នែកក្បាលបីដង មាត់និងធ្មេញម្ដង ពោះម្ដង ។ ផ្នែកក្បាលនោះគឺ :

លើកទី ១ កាលមិនទាន់ដឹងក្ដី រត់ប្រណាំងជាមួយបងប្រុស ទៅរកអ្នកម្ដាយនៅឯចង្ក្រាន ដួលបោកនឹងជ្រុញ បែកត្រង់រង្វេល ក្បាលចំពីខាងលើ, រឿងនេះខ្ញុំមិនចាំទេ ។

លើកទី ២ អាយុប្រហែល ៧ ឆ្នាំ នៅចាំបានថា រសៀលថ្ងៃ មួយ ខ្ញុំបានហូបបាយកកនៅឯចង្ក្រាន ពាងលើផ្ទះអស់ទឹក ខ្ញុំក៏ចុះទៅ ផឹកទឹកក្នុងពាងខាងមុខផ្ទះ ។ គ្រាន់តែដាក់ជើងចុះស្រោប់តែរបូតដៃធ្លាក់ ក្បាលទៅមុនបោកនឹងជ្រុញទ្រាប់ជើងទំហំប្រហែលពីរចំអាម ៤ ជ្រុង ត្រូវចំក្បាលខាងស្ដាំ ដែលមើលឃើញស្នាមរហូតសព្វថ្ងៃនេះ ។ ដោយត្រូវខ្លាំងពេក មិនឈឺទេ ទៅជាស្ពឹកអស់ ខ្ញុំខំក្រោកឈរឡើង